# កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះត្រូវបានព្រមព្រៀង និងចុះហត្ថលេខាដោយសណ្ឋាគារ ផាកហៃយ៉ាត់ សៀមរាប និង សហជីពនិយោជិក សណ្ឋាគារផាកហៃយ៉ាត់ ក្រោមលក្ខខណ្ឌដូចខាងក្រោម។

ដោយសារយើងមិនអាចមើលឃើញទុកជាមុននូវដំណើរការអាជីវកម្មរបស់យើងនាពេលអនាគត សណ្ឋាគារនឹងនៅបន្តបិទប្រតិបត្តិការរបស់ខ្លួនរហូតដល់មានការជូនដំណឹងបន្ថែម ដោយសារជំងឺ Covid-19។

ចាប់ពីថ្ងៃទី៦ ខែសីហា ឆ្នាំ ២០២០ ដល់ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ បុគ្គលិកនឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- បុគ្គលិកដែលមានតំណែងចាប់ពី Assistant Manager ឡើងទៅ នឹងទទួលបាន ៣0% នៃប្រាក់ខែគោល និងតម្រូវឲ្យធ្វើការ ៣0% នៃថ្ងៃធ្វើការ រហូតដល់ថ្ងៃដែលសណ្ឋាគារបើកដំណើរការ។
- បុគ្គលិក ដែលមានតំណែងជា Team Leader និងបុគ្គលិកធម្មតា នឹងទទួលបានប្រាក់ខែគោលចំនួន ៥0% នឹងត្រូវធ្វើការ ៥0% នៃថ្ងៃធ្វើការ រហូតដល់ថ្ងៃដែលសណ្ឋាគារបើកដំណើរការ។
- បុគ្គលិកដែលគ្មានច្បាប់ឈប់សម្រាកប្រចាំឆ្នាំ (AL) នឹងតម្រូវឱ្យធ្វើការតាមភាគរយសមស្របណាមួយ (%) នៃថ្ងៃធ្វើការ និងមានសិទ្ធិទទួលបានប្រភេទប្រាក់ខែខាងលើ។
- បុគ្គលិក ដែលនៅមានច្បាប់ឈប់សម្រាកប្រចាំឆ្នាំនៅសល់ (AL) គឺតម្រូវឲ្យប្រើច្បាប់សម្រាកប្រចាំឆ្នាំដែលនៅសល់នោះឲ្យអស់ ផ្អែកលើថ្ងៃធ្វើការរបស់ពួកគេ និងមានសិទ្ធិទទួលបានប្រភេទប្រាក់ខែខាងលើ។
- ប្រសិនបើនិយោជិកណាម្នាក់ត្រូវបានចាត់ឱ្យធ្វើការនៅចំថ្ងៃបុណ្យ បុគ្គលិកនោះនឹងយកថ្ងៃណាមួយក្នុងខែដដែលឈប់សម្រាកជំនួសនឹងថ្ងៃធ្វើការចំថ្ងៃបុណ្យវិញ។
- បុគ្គលិក អ្នកដែលមានកាលវិភាគការងារ ត្រូវមកធ្វើការតាមកាលវិភាគការងារដែលបានកំណត់ក្នុង "ថ្ងៃធ្វើការដែលមានប្រាក់ឈ្នួល" ។
- ក្នុងអំឡុងពេលនេះ អត្ថប្រយោជន៍ទាំងអស់ដែលមានចែងក្នុង CBA ត្រូវបានពន្យារក្សាទុកសិន។
- បុគ្គលិកទាំងអស់នឹងបន្តទទួលបានអត្ថប្រយោជន៍ផ្សេងទៀតដូចជា៖ ការធានារ៉ាប់រងសុខភាព ការថែរក្សាសុខភាពធ្មេញ និងការធានារ៉ាប់រងពី (ក្រុមហ៊ុន Infinity និងNSSF) ។

ជំនួសមុខ និងតាងនាមឲ្យ
សណ្ឋាគារ ផាក ហៃយ៉ាត់សៀមរាប

ព្រះរាជាណាចក្រកម្ពុជា
សណ្ឋាគារ ដឺឡា ពេ
HÔTEL DE LA PAIX
Co.,Ltd.
ខេត្តសៀមរាប

______________
ប្រាវីន គូម៉ារ
នាយកចាត់ការទូទៅ

ជំនួសមុខ និងតាងនាមឲ្យ
សហជីពនិយោជិកទេសចរណ៍សណ្ឋាគារ ផាកហៃយ៉ាត់

______________
ជុត ស៊ីថេត
ប្រធាន

សាក្សី

______________
ម៉ារីយ៉ូ ម៉ារីយ៉ាប៉ាន់
នាយកផ្នែកធនធានមនុស្ស

______________
កែវ សុខា
ប្រធាន